EFF'S SURVEILLANCE SELF-DEFENSE

# វិធីប្រើប្រាស់កម្មវិធីស៊ីហ្គណាល សម្រាប់ iOS

https://ssd.eff.org/en/about-surveillance-self-defense

ELECTRONIC FRONTIER FOUNDATION

LOCALIZATION LAB

# វិធីប្រើប្រាស់កម្មវិធីស៊ីហ្គណាល សម្រាប់ iOS

*សេចក្តីណែនាំនេះត្រូវបានសម្រួលពីការការពារខ្លួនពីការឃ្លាំមើលរបស់មូលនិធិ Electronic Frontier Foundation៖
https://ssd.eff.org/en/module/how-use-signal-android

ស៊ីហ្គណាល ជាកម្មវិធីឥតគិតថ្លៃ និងបើកទូលាយ សម្រាប់ Android iOS និងកុំព្យូទ័រ ដែលប្រើប្រាស់កូដនីយកម្មទាំងសងខាង។ ស៊ីហ្គណាល អនុញ្ញាតឲ្យអ្នកប្រើប្រាស់ផ្ញើសារជាអក្សរ រូបភាព សំឡេង វីដេអូ និងមានការសន្ទនាសម្ងាត់រវាងអ្នកប្រើប្រាស់ស៊ីហ្គណាលដូចគ្នា។ ទោះបីជា ស៊ីហ្គណាល ប្រើប្រាស់លេខទូរស័ព្ទសម្រាប់ទាក់ទងក៏ដោយ ការហៅនិងផ្ញើសារសម្ងាត់ប្រើប្រាស់ការតភ្ជាប់ទិន្នន័យរវាងភាគីសងខាង ត្រូវការប្រើប្រាស់អ៊ីនធឺណេត នៅក្នុងទូរស័ព្ទ។ ដោយហេតុផលនេះហើយ អ្នកប្រើប្រាស់ស៊ីហ្គណាលមិនត្រូវបានបង់ថ្លៃលើសារ SMS និង MMS សម្រាប់ប្រភេទសន្ទនានោះទេ។

**ទីតាំងសម្រាប់ទាញយក ៖** អ្នកប្រើប្រាស់អាចទាញយក កម្មវិធីបានពី Apple App Store។

**លក្ខខណ្ឌតម្រូវតាមប្រព័ន្ធ៖** iOS ៩.០ ឬជំនាន់ក្រោយ។ អាចប្រើបានជាមួយ iPhone, iPad, and iPod touch។

**ជំនាន់ដែលប្រើប្រាស់ជាគំរូក្នុងសេចក្តីណែនាំនេះគឺ** ស៊ីហ្គណាល iOS 2.23.4។

**អជ្ញាប័ណ្ណ៖** GPLv3

ការអានបន្ថែម៖
- https://signal.org/
- https://support.signal.org/
- https://signal.org/blog/

**កំរិត៖** អ្នកប្រើប្រាស់ពីកំរិតដំបូង ទៅធម្យម

**ថេរវេលាសម្រាប់តំឡើង៖** ពី ១៥ ទៅ ២០ នាទី

**ការកែសម្រួលចុងក្រោយ៖** ថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៨

## ការផ្លាស់ប្តូរទៅភាសារខ្មែរ

ប្រសិនបើអ្នកចង់ប្រើ ស៊ីហ្គណាលជាភាសាខ្មែរ អ្នកត្រូវតែប្តូរភាសាតាមរបៀបដូចខាងក្រោម៖

ដំបូង សូមចុចលើរូបតំណាង «ការកំណត់»




បន្ទាប់មក ចុចលើរូបតំណាង «ទូទៅ»




ជំហានបន្ទាប់ សូមចុចលើប៊ូតុង «ភាសា និង តំបន់»




ក្រោយមកសូមចុចលើប៊ូតុង«កែ»




ចុងក្រោយ សូមចុចលើប៊ូតុង «ខ្មែរ» សម្រាប់ប្តូរយកភាសាខ្មែរ ។




# ការដំឡើង ស៊ីហ្គណាល- សារឯកជននៅ លើទូរស័ព្ទ iPhone របស់អ្នក

## ជំហានទី ១ ៖ ទាញយក និងដំឡើងកម្មវិធី ផ្ញើសាស៊ីហ្គណាលឯកជន

នៅលើឧបករណ៍ iOS របស់អ្នក ចុចលើ App Store ហើយស្វែងរកស៊ីហ្គណាល។ ជ្រើសរើសកម្មវិធី ស៊ីហ្គណាល នៅលើ Open Whisper Systems។

ចុចលើពាក្យ "GET" ដើម្បីទាញយកកម្មវិធី បន្ទាប់មក  "INSTALL" អ្នកអាចផ្ទៀងផ្ទាត់ បញ្ចូលApple ID របស់អ្នក។ ពេលវាត្រូវបានដំឡើង ចុច “OPEN” ដើម្បីបើកកម្មវិធី។

## ជំហានទី២៖ ចុះឈ្មោះ និងផ្ទៀងផ្ទាត់លេខទូរស័ព្ទ របស់អ្នក

ឥឡូវអ្នកនឹងឃើញ អេក្រង់ដូចខាងក្រោម។ បញ្ចូលលេខទូរស័ព្ទរបស់អ្នក និងចុច “បើកប្រើប្រាស់លើឧបករណ៍នេះ ”។










អ្នកនឹងត្រូវបានគេផ្ញើនូវសារដែលមានលេខកូដប្រាំមួយខ្ទង់ ដើម្បីផ្ទៀងផ្ទាត់លេខទូរស័ព្ទរបស់អ្នក។ ឥឡូវអ្នកនឹងត្រូវបានឱ្យបញ្ចូលលេខកូដនេះ ហើយបន្ទាប់មកចុច “ដាក់ស្នើ”។




ស៊ីហ្គណលនឹងស្នើសុំការអនុញ្ញាត ដើម្បីផ្ញើការជូនដំណឹងដល់អ្នក។ សូមចុច “យល់ព្រម”។




# ជំហានទី៣៖ ជ្រើសរើសឈ្មោះ និងរូបតំណាង

រូបភាពតំណាងនិងឈ្មោះដែលអ្នកជ្រើសរើសនឹងត្រូវបានបង្ហាញនៅបញ្ជីទំនាក់ទំនងដែលអ្នកបានរក្សាទុកនៅក្នុងសៀវភៅអាសយដ្ឋានរបស់អ្នក នៅពេលដែលអ្នកចាប់ផ្តើមសន្ទនាថ្មី

និងនៅពេលដែលអ្នកអនុញ្ញាតឲ្យអ្នកទំនាក់ទំនង ឬក្រុមជាក់លាក់មើលព័ត៌មាននេះ។
បញ្ចូលព័ត៌មានដែលទាក់ទងផ្សេងៗនៅក្នុងជំហាននេះ បន្ទាប់មកចុច “រក្សាទុក” ឬ
ចុចរំលងចោលលើពាក្យ “រំលង” នៅខាងលើ។




# ការប្រើប្រាស់ស៊ីហ្គណាល

ដើម្បីអាចប្រើប្រាស់ស៊ីហ្គណាលបាន អ្នកដែលទាក់ទងជាមួយអ្នកត្រូវតែដំឡើងស៊ីហ្គណាលដែរ។
ប្រសិនបើអ្នកព្យាយាមផ្ញើសារទៅអ្នកដែលប្រើប្រាស់ស៊ីហ្គណាល
ហើយពួកគេមិនបានដំឡើងស៊ីហ្គណាល នោះវានឹងផ្ញើសារដោយមិនសម្ងាត់។
បើអ្នកព្យាយាមហៅទៅលេខនរណាម្នាក់ វានឹងប្ដូរទៅជាការហៅចេញធម្មតា។

ស៊ីហ្គណាលផ្តល់ឲ្យអ្នកនូវបញ្ជីរបស់អ្នកប្រើប្រាស់ផ្សេងទៀតដែលអ្នករក្សាលេខទុកក្នុងទូរស័ព្ទរបស់អ្នក។
ទិន្នន័យតំណាងឲ្យលេខទូរស័ព្ទនៅក្នុងបញ្ជីឈ្មោះរបស់អ្នកត្រូវបានបញ្ជូនទៅក្នុងបណ្ដាញស៊ីហ្គណាល
ប៉ុន្តែទិន្នន័យនេះគឺត្រូវបានលុបយ៉ាងបន្ទាន់។

## របៀបផ្ញើសារសម្ងាត់

ចូរចំណាំថា Open Whisper Systems អ្នកបង្កើតស៊ីហ្គណាល
ប្រើប្រាស់ធនធានរបស់ក្រុមហ៊ុនផ្សេងទៀតដើម្បីផ្ញើសារទៅរំលឹកអ្នកដែលប្រើប្រាស់
នៅពេលដែលពួកគេទទួលបានសារថ្មី។ ពួកគេប្រើប្រាស់ Google លើ Android និង Apple លើ iPhone
ដែលមានន័យថា ព័ត៌មានអ្នកដែលទទួលសារ និងនៅពេលដែលពួកគេបានទទួល
ប្រហែលជាលេចធ្លាយទៅក្រុមហ៊ុនទាំងនោះ។

ដើម្បីចាប់ផ្តើម ចុចលើរូបតំណាងបង្កើតថ្មីនៅជ្រុងខាងស្តាំផ្នែកខាងលើនៃអេក្រង់។




ស៊ីហ្គណលនឹងទាមទារការអនុញ្ញាតដើម្បីចូលប្រើប្រាស់លេខទូរស័ព្ទដែលរក្សាទុកក្នុងទូរស័ព្ទរបស់អ្នក។ ចុច OK ប្រសិនបើអ្នកយល់ព្រម។ ប្រសិនបើអ្នកមិនយល់ព្រម អ្នកអាចបញ្ចូលលេខទូរស័ព្ទរបស់អ្នកទំនាក់ទំនងដោយដៃ។




អ្នកនឹងឃើញបញ្ជីឈ្មោះទាំងអស់របស់អ្នកដែលបានចុះឈ្មោះប្រើប្រាស់ស៊ីហ្គណលនៅក្នុងកន្លែងរក្សាទុកលេខទូរស័ព្ទរបស់អ្នក។




នៅពេលដែលអ្នកចុចលើលេខទូរស័ព្ទដែលបានរក្សាទុក
អ្នកនឹងចូលទៅអេក្រង់សរសេរសារសំរាប់ការទំនាក់ទំនងរបស់អ្នក។
នៅលើអេក្រង់នេះអ្នកអាចផ្ញើសារ ជារូបភាព ឬវីដេអូ សំងាត់បាន។



# របៀបចាប់ផ្ដើមការសន្ទនាសម្ងាត់

ដើម្បីចាប់ផ្ដើមការសន្ទនាសម្ងាត់ជាមួយដៃគូរបស់អ្នក សូមជ្រើសរើសយកឈ្មោះដៃគូរបស់អ្នក បន្ទាប់មកចុចលើប៊ូតុងដែលមានរូបទូរស័ព្ទ




នៅចំណុចនេះ ប្រព័ន្ធស៊ីហ្គណល អាចសុំការអនុញ្ញាតពីអ្នកក្នុងការចូលប្រើប្រាស់ម៉ៃក្រូហ្វូន។ សូមអ្នកចុចប៊ូតុង «អូខេ» ដើម្បីអនុញ្ញាតឱ្យស៊ីហ្គណល ប្រើប្រាស់មៃក្រូហ្វូន




នៅពេលដែលអ្នកធ្វើការហៅទូរស័ព្ទ ការសន្ទនាតាមទូរស័ព្ទនោះនឹងក្លាយជាការសម្ងាត់

# របៀបចាប់ផ្តើមការហៅតាមវីដេអូដោយសម្ងាត់

អ្នកអាចហៅទៅនរណាម្នាក់ជាវីដេអូដោយសម្ងាត់ ដូចការរៀបរាប់ខាងក្រោម៖



បន្ទាប់មក ចុចរូបកាមេរ៉ាវីដេអូ។ អ្នកត្រូវតែអនុញ្ញាតឱ្យស៊ីហ្គណាល ចូលប្រើប្រាស់កាមេរ៉ា និងម៉ៃក្រូហ្វូនរបស់អ្នក។ ការធ្វើដូចនេះ អាចឱ្យអ្នកចែករំលែកវីដេអូជាមួយមិត្តភក្តិរបស់អ្នក ហើយមិត្តភ័ក្តិរបស់អ្នកប្រហែលត្រូវធ្វើដូចគ្នាដែរ៖




## របៀបចាប់ផ្តើមការជជែកសម្ងាត់ជាក្រុម

អ្នកអាចផ្ញើសារសម្ងាត់តាមក្រុម ដោយចុចរូបផ្ញើ នៅជ្រុងខាងលើ ផ្នែកខាងស្តាំនៃអេក្រង់ (ប្រអប់ដែលមានខ្មៅដៃ នៅកណ្តាល) បន្ទាប់មកចុចលើរូបតំណាងនេះ ដូចបង្ហាញក្នុងរូបទាំង៣។







នៅអេក្រង់ខាងក្រោម អ្នកនឹងអាចដាក់ឈ្មោះក្រុម និងបន្ថែមអ្នកចូលរួម។ បន្ទាប់មក អ្នកអាចចុច “បង្កើត” នៅខាងលើ ផ្នែកខាងស្ដាំនៃអេក្រង់។




នេះនឹងបង្កើតក្នុងជជែកថ្មី។




បើអ្នកចង់ផ្លាស់ប្តូរឈ្មោះក្រុម រូបតំណាង ឬបន្ថែមអ្នកចូលរួម នេះអាចធ្វើបាន នៅផ្ទាំងជជែក ដោយចុចលើឈ្មោះក្រុម និងជ្រើសរើស “កែប្រែក្រុម”។

# បិទសំឡេងការសន្ទនា

ពេលខ្លះការសន្ទនាអាចរំខាន។
លក្ខណៈពិសេសមួយដែលមានប្រយោជន៍សម្រាប់ការជជែកជាក្រុម ត្រូវបានផ្លាស់ប្តូរការជូនដំណឹង ដូច្នេះអ្នកមិនឃើញការជូនដំណឹងថ្មីរាល់ពេលសារថ្មីត្រូវបានទេ។
នេះអាចធ្វើបានពីផ្ទាំងជជែកជាក្រុមដោយចុចរូបតំណាងលើឈ្មោះក្រុម និងជ្រើសរើស "ការជូនដំណឹងដោយគ្មានសំឡេង " ។

បន្ទាប់មកអ្នកអាចជ្រើសរយៈពេលដែលអ្នកចង់ឱ្យបិទសកម្មភាព។
ដំណើរការនេះអាចត្រូវបានអនុវត្តចំពោះការសន្ទនាបុគ្គលផងដែរ បើអ្នកចង់។

# វិធីផ្ទៀងផ្ទាត់លេខទំនាក់ទំនងរបស់អ្នក

នៅក្នុងចំណុចនេះ អ្នកអាចផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃបុគ្គលដែលអ្នកមានទំនាក់ទំនងជាមួយ ដើម្បីប្រាកដថាកូដនីយកម្មរបស់ពួកគេត្រឹមត្រូវមិនត្រូវបានក្លែងបន្លំពីអ្នកដទៃនៅពេលដែលអ្នកទាញយកកម្មវិធីនេះ (ដំណើរការនេះហៅថាការផ្ទៀងផ្ទាត់កូដនីយកម្ម)។ ការផ្ទៀងផ្ទាត់ គឺជាដំណើរការមួយដែលអ្នកត្រូវធ្វើចំពោះមុខម្ចាស់គណនី។

ដំបូង បើកអេក្រង់ដែលអ្នក ផ្ញើសារទៅលេខទំនាក់ទំនង របស់អ្នកដូចដែលបានរៀបរាប់ខាងលើ។
នៅលើកអេក្រង់នេះ ចុចឈ្មោះដែលអ្នកចង់ទំនាក់ទំទងនៅផ្នែកខាងលើនៃអេក្រង់។




ដំបូង បើកអេក្រង់ដែលអ្នក ផ្ញើសារទៅលេខទំនាក់ទំនង របស់អ្នកដូចដែលបានរៀបរាប់ខាងលើ។
នៅលើកអេក្រង់នេះ ចុចឈ្មោះដែលអ្នកចង់ទំនាក់ទំទងនៅផ្នែកខាងលើនៃអេក្រង់។




លើអេក្រង់ខាងក្រោមនេះ ចុចលើ “បង្ហាញលេខកូដសុវត្ថិភាព”




ឥឡូវនេះអ្នកដាក់អេក្រង់ដែលបង្ហាញ QR កូដ និងលេខសុវត្ថិភាព។ កូដសំខាន់នេះនឹងមានតែមួយគត់រាល់ការទំនាក់ទំនងផ្សេងៗដែលអ្នកសន្ទនាជាមួយ។ បើមនុស្សដែលអ្នកកំពុងទាក់ទង កំពុងបើកអេក្រង់ដូចអ្នក នោះគេមានកូដ QR ដែលបង្ហាញលើអេក្រង់ដូចគ្នា។




ចូលទៅកាន់កម្មវិធីរបស់អ្នក អ្នកអាចចុចលើ QR កូដរបស់អ្នកដើម្បីស្កេន។ នៅត្រង់ចំនុចនេះ ស៊ីណ្ណលអាចសុំការអនុញ្ញាតពីអ្នកដើម្បីដំណើរការម៉ាស៊ីនថត ដូចនេះ សូមចុច “យល់ព្រម”។




ឥលូវ អ្នកនឹងអាចប្រើប្រាស់ ម៉ាស៊ីនថតដើម្បីថតយក QR កូដដែលបង្ហាញលើអេក្រង់ទំនាក់ទំនាក់ទំនងរបស់អ្នក។ តម្រង់ម៉ាស៊ីនថតរបស់អ្នកឲ្យត្រូវនឹងQR កូដ៖




សង្ឃឹមថា កាមេរ៉ារបស់អ្នកនឹងអាចស្កេន QRកូដ និង បង្ហាញ “លេខសុវត្ថិភាពត្រូវគ្នា”ដូចនេះ៖




នេះបង្ហាញថាអ្នកបានផ្ទៀងផ្ទាត់ការទាក់ទងរបស់អ្នកបានជោគជ័យ។អ្នកគួរចុចរំកិលបន្ទាប់សម្រាប់ “ផ្ទៀងផ្ទាត់” ដើម្បីឲ្យកម្មវិធីចងចាំថាទំនាក់ទំនងរបស់អ្នកបានត្រូវផ្ទៀងផ្ទាត់រួចហើយ។ ប្រសិនបើអ្នកឃើញអេក្រង់បែបនេះ មានន័យថា អ្វីមួយខុសប្រក្រតី៖




អ្នកប្រហែលជាត្រូវជៀសវាងការពិភាក្សាប្រធានបទរសើបរហូតដល់អ្នកបានផ្ទៀងផ្ទាត់សោរសំងាត់ជាមួយមនុស្សនោះ។

ចំណាំ សម្រាប់អ្នកប្រើប្រាស់កម្រិតខ្ពស់៖ អេក្រង់ដែលបង្ហាញកូដ QR មានរូបតំណាងមួយដែលចែករំលែកលេខសុវត្ថិភាពនៅខាងលើផ្នែកខាងស្តាំ។ ការផ្ទៀងផ្ទាត់បុគ្គល ជាវិធីមួយ ប៉ុន្តែអ្នកប្រហែលជាបានផ្ទៀងផ្ទាត់លេខទំនាក់ទំនង ដោយប្រើប្រាស់កម្មវិធីសុវត្ថិភាពផ្សេង។ ដោយសារអ្នកបានផ្ទៀងផ្ទាត់លេខទំនាក់ទំនង អ្នកអាចទុកចិត្តកម្មវិធីក្នុងការផ្ទៀងផ្ទាត់លេខក្នុងស៊ីហ្គណាល ដោយមិនចាប់មានក្នុងបញ្ជីទំនាក់ទំនង។ ក្នុងករណីនេះ អ្នកអាចចែករំលែកលេខសុវត្ថិភាពក្នុងកម្មវិធីនេះ ដោយចុច រូបតំណាង “ចែករំលែក” និងបញ្ជូនលេខសុវត្ថិភាពរបស់អ្នក។

# សារដែលលុបដោយខ្លួនឯង

ប្រព័ន្ធស៊ីហ្គណាលមានជម្រើសមួយផ្សេងទៀតដែលគេហៅថា «សារលុបដោយខ្លួនឯង» ដែលធានាថាពល់សារទាំងអស់នឹងត្រូវបានលុបចោលចេញពីទូរស័ព្ទរបស់អ្នក និងទូរស័ព្ទដៃគូរសន្ទនារបស់អ្នក នៅពេលជាក់លាក់ណាមួយបន្ទាប់ពីអ្នកបានអានសារនោះហើយ ។ ដើម្បីដំណើរការជម្រើសនេះ សូមចូលទៅកាន់ប្រព័ន្ធស៊ីហ្គណាល់ បន្ទាប់មកចុចលើអេក្រង់ដែលអ្នកអាចធ្វើការផ្ញើសារទៅកាន់ដៃគូរសន្ទនារបស់អ្នក ។ ក្រោយមកសូមចុចឈ្មោះដៃគូរសន្ទនាដែលនៅលើអេក្រង់ ហើយចុចសញ្ញារំកិលដែលនៅជិតពាក្យ «សារលុបដោយខ្លួនឯង» ។




សញ្ញារំកិលនឹងលោតឡើង ដែលអនុញ្ញាតិឲ្យអ្នកជ្រើសរើសរយៈពេលដែលសារទាំងនោះត្រូវលុបះ




បន្ទាប់ពីជ្រើសរើសយកជំរើសនេះ អ្នកអាចចុចលើរូប “<” នៅផ្នែកលើខាងឆ្វេងនៃអេក្រង់ ហើយអ្នកគួរតែឃើញព័ត៌មាននៅក្នុងការសន្ទនា ដែលបញ្ជាក់ថា “ការលុបសារ” ត្រូវបានបើក។




ឥឡូវនេះ អ្នកអាចផ្ញើសារដោយប្រាកដថា សារទាំងនោះនឹងត្រូវលុបចេញ បន្ទាប់ពីរយៈពេលដែលអ្នកបានកំណត់។